**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**ធនាគារជាតិ នៃ កម្ពុជា**

# សេចក្តីថ្លែងការណ៍រួម
# រវាង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ធនាគារជាតិនៃកម្ពុជា

នាពេលកន្លងមកនេះ រាជរដ្ឋាភិបាលបានសង្កេតឃើញថា ប្រជាពលរដ្ឋមួយចំនួន ជាពិសេស នៅតំបន់ជនបទ តែងតែមានការយល់ច្រឡំថា ធនាគារពាណិជ្ជ ធនាគារឯកទេស គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ និងប្រតិបត្តិករឥណទានជនបទ ជាគ្រឹះស្ថានរបស់រដ្ឋ ។

ដើម្បីចៀសវាងការយល់ច្រឡំខាងលើ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា សូមបំភ្លឺជូនសាធារណជនជ្រាបថា ៖

១. ធនាគារពាណិជ្ជ ធនាគារឯកទេស គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ និងប្រតិបត្តិករឥណទានជនបទទាំងអស់ ដែលទទួលអាជ្ញាបណ្ណប្រកបអាជីវកម្មពីធនាគារជាតិនៃកម្ពុជា គឺជាគ្រឹះស្ថានដែលកាន់កាប់ និងគ្រប់គ្រងដោយឯកជន មិនមែនជារបស់រដ្ឋឡើយ ។

២. គ្រឹះស្ថានទាំងនោះ គឺជាក្រុមហ៊ុនឯកជន ដែលត្រូវតែស្វែងរកប្រាក់ចំណេញសម្រាប់ទ្រទ្រង់និរន្តរភាពប្រតិបត្តិការរបស់ខ្លួន ។

៣. ប្រជាពលរដ្ឋដែលខ្ចីប្រាក់ពី ធនាគារពាណិជ្ជ ធនាគារឯកទេស គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ និងប្រតិបត្តិករឥណទានជនបទ ត្រូវមានកាតព្វកិច្ចសងប្រាក់កម្ចីវិញ ។ ការមិនគោរពកាតព្វកិច្ចសងប្រាក់កម្ចី

វិញ អាចប៉ះពាល់ជាអវិជ្ជមានដល់កេរ្តិ៍ឈ្មោះរបស់អ្នកខ្ចីប្រាក់ និងមិនអាចទទួលបានប្រាក់កម្ចីថ្មីបន្ថែមទៀតសម្រាប់បំពេញតម្រូវការនាពេលក្រោយ ។

៤. ធនាគារអភិវឌ្ឍន៍ជនបទ គឺជាធនាគាររបស់រដ្ឋតែមួយគត់ ដែលបានរួមចំណែកផ្តល់ប្រាក់កម្ចីដល់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ព្រមទាំងគាំទ្រការផ្តល់ប្រាក់កម្ចីដល់វិស័យកសិកម្ម វិស័យកសិ-ឧស្សាហកម្ម សហគ្រាសធុនតូចនិងមធ្យម និងផ្តល់ប្រាក់កម្ចីបន្តដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។ ទោះជាយ៉ាងណាក៏ដោយ ប្រជាពលរដ្ឋដែលជំពាក់ប្រាក់ធនាគារនេះ ត្រូវមានកាតព្វកិច្ចសងប្រាក់មកធនាគារវិញ ។

៥. ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា សង្ឃឹមនិងជឿជាក់ថា អាជ្ញាធរមូលដ្ឋាន នឹងសហការចូលរួមផ្សព្វផ្សាយ និងអប់រំប្រជាពលរដ្ឋ កុំឱ្យយល់ច្រឡំថា ធនាគារពាណិជ្ជ ធនាគារឯកទេស គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ និងប្រតិបត្តិករឥណទានជនបទ ជារបស់រដ្ឋ និងដើម្បីចៀសវាងការឃោសនាភូតកុហករបស់ជនអគតិបន្តទៀត ។

៦. ជនណាដែលដើរឃោសនាបោកប្រាស់ប្រជាពលរដ្ឋអំពីបញ្ហាលុបបំណុល នឹងត្រូវទទួលទោសតាមផ្លូវច្បាប់ជាធរមាន ។៕

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ២០១៧